**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៩១ អនក្រ.បក**

ក្រសួងមហាផ្ទៃ
អគ្គលេខាធិការដ្ឋាន
ចូល
លេខ 080
ថ្ងៃ 17-10-25 9h:30
ម៉ោង

# អនុក្រឹត្យ

## ស្ដីពី

## ការគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីអស្សាមិករណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីផ្លូវថ្នល់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៧/០០២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៥

- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីយន្តការនិងវិធាននៃការគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងការសាងសង់ផ្លូវឆ្លងកាត់ផ្លូវដែក និងការពារលុបបំបាត់បាតុភាពរំលោភដីចំណីផ្លូវដែក បង្កលក្ខណៈងាយស្រួលដល់សមត្ថកិច្ចពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងសណ្តាប់ធ្នាប់និងកំណត់ភាពស្របច្បាប់ដល់ពលរដ្ឋដែលជាម្ចាស់កម្មសិទ្ធិអចលនទ្រព្យនៅតាមបណ្តាញផ្លូវដែក បង្កើតស្តង់ដានិងបច្ចេកវិទ្យាសមស្របសម្រាប់ប្រព័ន្ធការពារផ្លូវដែក ផ្លាកសញ្ញាផ្សេងៗ ឧបករណ៍ផ្តល់ដំណឹង ក្នុងគោលបំណងរួមចំណែកទប់ស្កាត់ឧបទ្ទវហេតុគ្រោះថ្នាក់ ថែរក្សាបាននូវគុណភាពផ្លូវដែក និងបង្កលក្ខណៈងាយស្រួលដល់ចរាចរណ៍តាមផ្លូវដែក។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពលើការគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី២

## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៤ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូនមានសមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រសួងសាធារណការនិងដឹកជញ្ជូនត្រូវសហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្តពាក់ព័ន្ធ ដើម្បីធានាការពាររាល់ទ្រព្យសម្បត្តិផ្លូវដែក ដូចជាឋបនីយកណ្ឌផ្លូវដែក បណ្តាញផ្លូវដែក ដីចំណីផ្លូវដែក សម្ភារៈយានផ្លូវដែក សំណង់សិល្បការ្យផ្លូវដែក នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យមានប្រសិទ្ធភាព។

## ជំពូកទី៣
## ការសាងសង់ផ្លូវឆ្លងកាត់ផ្លូវដែក
### ផ្នែកទី១
### គោលការណ៍

**មាត្រា៥ .-**

រាល់ការសាងសង់ផ្លូវឆ្លងកាត់ផ្លូវដែកឬបើកផ្លូវឆ្លងកាត់ផ្លូវដែក ត្រូវគោរពតាមគោលការណ៍ដូចតទៅ៖

- **សុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់ផ្លូវឆ្លងកាត់ផ្លូវដែក** : ត្រូវរៀបចំវិធានការសុវត្ថិភាពនៅត្រង់ចំណុចផ្លូវឆ្លងកាត់ផ្លូវដែក ដើម្បីការពារសុវត្ថិភាពអ្នកប្រើប្រាស់ផ្លូវឆ្លងកាត់ផ្លូវដែកនោះ
- **ការផ្តល់ព័ត៌មានដល់អ្នកប្រើប្រាស់ផ្លូវថ្នល់ដែលឆ្លងកាត់ផ្លូវដែក** : ត្រូវផ្តល់ព័ត៌មានគ្រប់គ្រាន់និងសមស្របសម្រាប់អ្នកប្រើប្រាស់ផ្លូវ ដើម្បីបើកផ្លូវឆ្លងកាត់ផ្លូវដែកប្រកបដោយសុវត្ថិភាពនិងត្រូវតែបង្ហាញប្រាប់ ឬធ្វើការណែនាំឱ្យបានទូលំទូលាយដល់អ្នកប្រើប្រាស់ផ្លូវទាំងអស់
- **ការចាត់ចែងចំណុចផ្លូវឆ្លងកាត់ផ្លូវដែកដោយសុវត្ថិភាព** : ត្រូវរៀបចំចំណុចផ្លូវឆ្លងកាត់ផ្លូវដែកតាមលក្ខណៈបច្ចេកទេស ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### ផ្នែកទី២
### ផ្លូវឆ្លងកាត់ផ្លូវដែក

**មាត្រា៦ .-**

ផ្លូវឆ្លងកាត់ផ្លូវដែក ត្រូវបំពាក់ឧបករណ៍ត្រួតពិនិត្យចរាចរណ៍ ផ្លាកសញ្ញាផ្តល់ដំណឹង ឬផ្លាកសញ្ញាព្រមានចាំបាច់ ដើម្បីធានាសុវត្ថិភាពចរាចរណ៍។

ការដំឡើងឧបករណ៍ត្រួតពិនិត្យចរាចរណ៍ ផ្លាកសញ្ញាផ្តល់ដំណឹង ឬផ្លាកសញ្ញាព្រមាន ត្រូវអនុលោមតាមលក្ខខណ្ឌបច្ចេកទេសចាំបាច់ និងបំពាក់ទៅតាមសភាពជាក់ស្តែងនៃផ្លូវឆ្លងកាត់ផ្លូវដែក។

**មាត្រា៧ .-**

ដើម្បីបញ្ចៀសឧបទ្ទវហេតុនានានៅផ្លូវឆ្លងកាត់ផ្លូវដែក សមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក និងបុគ្គលដែលប្រើប្រាស់ច្រកផ្លូវឆ្លងកាត់ផ្លូវដែក ត្រូវចាត់វិធានការធានាសន្តិសុខនិងសុវត្ថិភាពដល់ការធ្វើចរាចរណ៍របស់រថភ្លើង តាមការកំណត់ដូចខាងក្រោម៖

១- តំបន់គ្រឹះស្ថានសិក្សា តំបន់រោងចក្រឬសហគ្រាស តំបន់សេវាកម្ម តំបន់ផលិតកម្ម តំបន់លំនៅឋាន និងតំបន់ប្រហាក់ប្រហែលផ្សេងទៀត ត្រូវចាត់ភ្នាក់ងារឬមនុស្សប្រចាំការត្រង់ផ្លូវឆ្លងកាត់ផ្លូវដែក និងត្រូវបំពាក់របាំងឬរបាំងការពារ រួមទាំងផ្លាកសញ្ញាបង្ហាញផ្លូវឆ្លងកាត់ផ្លូវដែកឱ្យបានត្រឹមត្រូវតាមបច្ចេកទេសកំណត់។

២- ផ្លាកសញ្ញារូបក្បាលរថភ្លើងដែលជាសញ្ញាសម្គាល់ថាផ្លូវឆ្លងកាត់ផ្លូវដែកខាងមុខគ្មានផ្ទាំងរបារ ត្រូវដំឡើងចម្ងាយ១០០(មួយរយ)ម៉ែត្រពីអ័ក្សផ្លូវដែកនៃផ្លូវឆ្លងកាត់ ឬតាមស្ថានភាពជាក់ស្តែងនៃផ្លូវដែក និងអាចឱ្យអ្នកប្រើប្រាស់ផ្លូវងាយមើលឃើញមុននឹងឆ្លងកាត់ផ្លូវដែក។

៣- ផ្លាកសញ្ញារូបរបារដែលជាសញ្ញាសម្គាល់ថាផ្លូវឆ្លងកាត់ផ្លូវដែកខាងមុខមានផ្ទាំងរបារ ត្រូវដំឡើងចម្ងាយ៣០០(បីរយ)ម៉ែត្រពីអ័ក្សផ្លូវដែកនៃផ្លូវឆ្លងកាត់ ឬតាមស្ថានភាពជាក់ស្តែងនៃផ្លូវដែក ដោយដំឡើងជាបីបង្គោលរៀងគ្នា ដែលមានចម្ងាយ១០០(មួយរយ)ម៉ែត្រពីបង្គោលមួយទៅបង្គោលមួយ និងអាចឱ្យអ្នកប្រើប្រាស់ផ្លូវងាយមើលឃើញមុននឹងឆ្លងកាត់ផ្លូវដែក។

៤- ផ្លាកសញ្ញាសុវត្ថិភាពត្រូវដំឡើងសងខាងលើផ្លូវឆ្លងកាត់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៥- ផ្លាកសញ្ញាចាំបាច់ផ្សេងទៀត ត្រូវដំឡើងនៅលើផ្លូវដែកអនុលោមតាមបទដ្ឋានបច្ចេកទេស។

សមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែកអាចដាក់ចេញនូវវិធានការមួយចំនួនផ្សេងទៀតតាមការចាំបាច់ជាក់ស្តែង ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៨ .-**

នៅពេលឮរថភ្លើងបន្លឺសញ្ញាជិតមកដល់ផ្លូវឆ្លងកាត់ផ្លូវដែក អ្នកបើកបរនិងអ្នកប្រើប្រាស់ផ្លូវទាំងអស់ត្រូវគោរពតាមវិធានការដូចខាងក្រោម៖

១- ត្រូវឈប់ចម្ងាយយ៉ាងតិច២(ពីរ)ម៉ែត្រពីរបារឬរបាំងការពារ និងត្រូវស្តាប់បញ្ជាឆ្មាំរបារ ដោយមិនត្រូវបង្កឧបសគ្គដល់ការបិទបើករបារឬរបាំងសុវត្ថិភាពឡើយ។

២- ត្រូវឈប់ចម្ងាយយ៉ាងតិច៥(ប្រាំ)ម៉ែត្រពីអ័ក្សផ្លូវដែក ក្នុងករណីគ្មានរបារឬរបាំងការពារ ដើម្បីទុកផ្លូវឱ្យរថភ្លើងធ្វើចរាចរណ៍។

៣- ត្រូវបញ្ឈប់ហ្វូងសត្វពាហនៈកុំឱ្យឆ្លងកាត់ មុនពេលរថភ្លើងជិតមកដល់កន្លែងផ្លូវឆ្លងកាត់ផ្លូវដែក ដើម្បីទុកផ្លូវឱ្យរថភ្លើងធ្វើចរាចរណ៍។

៤- ត្រូវរិះរកគ្រប់មធ្យោបាយដើម្បីបញ្ចៀសឧបសគ្គដល់ការធ្វើចរាចរណ៍របស់រថភ្លើងឬត្រូវឱ្យដំណឹងដល់ភ្នាក់ងារទទួលខុសត្រូវផ្លូវដែកដែលនៅជិតបំផុត ក្នុងករណីមានយានគាំងដំណើរលើផ្លូវដែក ឬហ្វូងសត្វចូលមកជ្រុលលើផ្លូវដែក។

អ្នកបើកបរឬអ្នកប្រើប្រាស់ផ្លូវទាំងអស់ ត្រូវទទួលខុសត្រូវរាល់ការខូចខាតទាំងឡាយដែលកើតចេញពីអំពើល្មើសនឹងវិធានដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៣
## ប្រភេទនិងចំណាត់ថ្នាក់កម្រិតផ្លូវឆ្លងកាត់ផ្លូវដែក

**មាត្រា៩ .-**

ប្រភេទកម្រិតផ្លូវឆ្លងកាត់ផ្លូវដែករវាងផ្លូវដែកនិងផ្លូវថ្នល់ ត្រូវបានបែងចែកដូចខាងក្រោម៖

១- ផ្លូវឆ្លងកាត់ផ្លូវដែកដែលប្រើប្រាស់ជាសាធារណៈ ដូចជាផ្លូវល្បឿនលឿន ផ្លូវជាតិ ផ្លូវខេត្ត ផ្លូវរាជធានី ផ្លូវក្រុង ស្រុក ខណ្ឌ ផ្លូវទីប្រជុំជននានា និងផ្លូវជនបទ។

២- ផ្លូវឆ្លងកាត់ផ្លូវដែកដែលប្រើប្រាស់ជាលក្ខណៈបុគ្គលដែលជាកម្មសិទ្ធិឯកជន សម្រាប់ការសាងសង់ផ្លូវចេញចូលឆ្លងកាត់ផ្លូវដែក។ ចំពោះផ្លូវឆ្លងកាត់ផ្លូវដែកកម្រិតនេះ ត្រូវសាងសង់ដោយមានកិច្ចព្រមព្រៀងជាមួយសមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក។

៣- ផ្លូវឆ្លងកាត់ផ្លូវដែកដែលប្រើប្រាស់សម្រាប់ថ្មើរជើងនិង/ឬសត្វចិញ្ចឹមឆ្លងកាត់។ ចំពោះផ្លូវឆ្លងកាត់ផ្លូវដែកកម្រិតនេះត្រូវសាងសង់និងបំពាក់ឧបករណ៍ពិសេសនៅត្រង់ចំណុចផ្លូវឆ្លងកាត់ផ្លូវដែក ដើម្បីការពារថ្មើរជើងឬសត្វចិញ្ចឹមឆ្លងកាត់ផ្លូវដោយសុវត្ថិភាព។

៤- ផ្លូវផ្សេងទៀតដែលឆ្លងកាត់ផ្លូវដែក។

**មាត្រា១០.-**

ប្រភេទកម្រិតផ្លូវឆ្លងកាត់ផ្លូវដែកដូចមានចែងក្នុងមាត្រា៩នៃអនុក្រឹត្យនេះ ត្រូវបានធ្វើចំណាត់ថ្នាក់ដូចខាងក្រោម៖

- **ចំណាត់ថ្នាក់ទី១** កន្លែងផ្លូវឆ្លងកាត់ផ្លូវដែកដែលមានចលនាយានយន្តធ្វើចរាចរណ៍កម្រិតចាប់ពី ៥០ ០០០(ប្រាំម៉ឺន)គ្រឿងក្នុងមួយថ្ងៃ
- **ចំណាត់ថ្នាក់ទី២** កន្លែងផ្លូវឆ្លងកាត់ផ្លូវដែកដែលមានចលនាយានយន្តធ្វើចរាចរណ៍កម្រិតចាប់ពី ១០ ០០០(មួយម៉ឺន)គ្រឿង ទៅ៥០ ០០០(ប្រាំម៉ឺន)គ្រឿងក្នុងមួយថ្ងៃ
- **ចំណាត់ថ្នាក់ទី៣** កន្លែងផ្លូវឆ្លងកាត់ផ្លូវដែកដែលមានចលនាយានយន្តធ្វើចរាចរណ៍កម្រិតតិចជាង ១០ ០០០(មួយម៉ឺន)គ្រឿងក្នុងមួយថ្ងៃ
- **ចំណាត់ថ្នាក់ទី៤** កន្លែងផ្លូវឆ្លងកាត់ផ្លូវដែកដែលចេញពីទីតាំងដីកម្មសិទ្ធិឯកជន។

លក្ខខណ្ឌបច្ចេកទេសនៃការធ្វើចំណាត់ថ្នាក់និងការចុះបញ្ជីប្រភេទផ្លូវឆ្លងកាត់ផ្លូវដែកខាងលើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

## ផ្នែកទី៤
## ការសាងសង់និងការជួសជុលថែទាំផ្លូវឆ្លងកាត់ផ្លូវដែក

**មាត្រា១១.-**

រាល់គម្រោងសាងសង់ ជួសជុល ថែទាំ និងកែសម្រួលផ្លូវឆ្លងកាត់ផ្លូវដែក ដូចមានចែងក្នុងមាត្រា៩និងមាត្រា១០នៃអនុក្រឹត្យនេះ ត្រូវស្នើសុំការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក។

សមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក មានសិទ្ធិបិទឬបញ្ឈប់ការសាងសង់ ការជួសជុល ការថែទាំ និងការកែសម្រួលផ្លូវឆ្លងកាត់ផ្លូវដែកណាមួយដែលរំខានផ្លូវដែកឬបង្កហានិភ័យដល់សុវត្ថិភាពចរាចរណ៍ផ្លូវដែក។

**មាត្រា១២.-**

រាល់ការសាងសង់និងការជួសជុលថែទាំផ្លូវឆ្លងកាត់ផ្លូវដែក ឬការដំឡើងនិងការបំពាក់ឧបករណ៍សុវត្ថិភាពផ្លូវឆ្លងកាត់ផ្លូវដែកនីមួយៗដូចមានចែងក្នុងមាត្រា៧នៃអនុក្រឹត្យនេះ ត្រូវអនុវត្តដូចខាងក្រោម៖

១- ការសាងសង់និងការជួសជុលថែទាំផ្លូវឆ្លងកាត់ផ្លូវដែក ឬការដំឡើងនិងការបំពាក់ឧបករណ៍សុវត្ថិភាពផ្លូវឆ្លងកាត់ផ្លូវដែកដែលប្រើប្រាស់ជាសាធារណៈ ឬផ្លូវឆ្លងកាត់ផ្លូវដែកប្រើប្រាស់សម្រាប់ថ្មើរជើង ឬសត្វចិញ្ចឹម ជាបន្ទុករបស់សមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក។

២- ការសាងសង់និងការជួសជុលថែទាំផ្លូវឆ្លងកាត់ផ្លូវដែកឬការដំឡើងនិងការបំពាក់ឧបករណ៍សុវត្ថិភាពផ្លូវឆ្លងកាត់ផ្លូវដែកប្រើប្រាស់ជាលក្ខណៈបុគ្គលកម្មសិទ្ធិឯកជន ជាបន្ទុករបស់បុគ្គលដែលស្នើសុំ។

បច្ចេកទេសនៃការសាងសង់និងការជួសជុលថែទាំផ្លូវឆ្លងកាត់ផ្លូវដែកឬការដំឡើងនិងការបំពាក់ឧបករណ៍សុវត្ថិភាពផ្លូវឆ្លងកាត់ផ្លូវដែក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា១៣.-**

រាល់ការសាងសង់ ការដំឡើង ឬការកែប្រែហេដ្ឋារចនាសម្ព័ន្ធបង្គោលបណ្តាញទូរគមនាគមន៍ បង្គោលបណ្តាញអគ្គិសនី បំពង់បណ្តាញទឹកស្អាត ប្រព័ន្ធលូ ប្រព័ន្ធបណ្តាញបំពង់បង្ហូរនិងចែកចាយផលិតផលប្រេងកាតនិងឧស្ម័នធម្មជាតិ និងបណ្តាញផ្សេងៗឆ្លងកាត់ផ្លូវដែក សម្រាប់បម្រើផលប្រយោជន៍សាធារណៈឬឯកជន ត្រូវស្នើសុំការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក។

ការអនុវត្តការងារដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមនិងត្រូវអនុវត្តតាមការណែនាំរបស់សមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក ព្រមទាំងចាត់វិធានការនានាដើម្បីធានាមិនឱ្យមានការខូចគុណភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកឬបង្កការរាំងស្ទះដល់ប្រតិបត្តិការនិងសុវត្ថិភាពចរាចរណ៍ផ្លូវដែក។

**មាត្រា១៤.-**

ការបិទផ្លូវឆ្លងកាត់ផ្លូវដែក ការកែសម្រួលផ្លូវឆ្លងកាត់ផ្លូវដែកបញ្ចូលគ្នា និងការបើកផ្លូវឆ្លងកាត់ផ្លូវដែកថ្មី ត្រូវតែឈរលើគោលការណ៍សុវត្ថិភាពសាធារណៈ ភាពចាំបាច់នៃការប្រើប្រាស់ច្រកចេញចូល និងសារៈសំខាន់សេដ្ឋកិច្ច ឬទីតាំងគ្មានជម្រើសផ្សេងទៀត។

បែបបទនិងនីតិវិធីនៃការស្នើសុំសាងសង់ថ្មី ជួសជុល ថែទាំ និងកែសម្រួលផ្លូវឆ្លងកាត់ផ្លូវដែក ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ។

ក្រសួងសាធារណការនិងដឹកជញ្ជូនអាចស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាល ដើម្បីបិទផ្លូវឆ្លងកាត់ផ្លូវដែក ឬកែសម្រួលផ្លូវឆ្លងកាត់ផ្លូវដែកដែលមិនសមស្របនឹងលក្ខខណ្ឌបច្ចេកទេសឬសាងសង់ដោយគ្មានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក។

## ជំពូកទី៤
## ការកំណត់ដីចំណីផ្លូវដែក
### ផ្នែកទី១
### គោលការណ៍

**មាត្រា១៥.-**

ដីចំណីផ្លូវដែក គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលត្រូវបម្រុងទុកប្រើប្រាស់ក្នុងការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តឬគោលបំណងផ្សេងទៀត។ ព្រំប្រទល់នៃដីចំណីផ្លូវដែកត្រូវកំណត់ក្នុងផែនការរៀបចំដែនដីនិងនគរូបនីយកម្ម ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងករណីដែលដីចំណីផ្លូវដែកត្រួតលើគ្នាជាមួយប្រភេទតំបន់ហាមឃាត់ផ្សេងទៀតឬតំបន់ការពារ ការរក្សាទុកដីចំណីផ្លូវដែកក្នុងកម្រិតអប្បបរមាមួយត្រូវបានកំណត់យ៉ាងជាក់លាក់ ក្រោមកិច្ចសហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

**មាត្រា១៦.-**

ការកំណត់ដីចំណីផ្លូវដែក ឈរលើគោលការណ៍ដូចខាងក្រោម៖

- លក្ខខណ្ឌបច្ចេកទេសនិងស្តង់ដាសុវត្ថិភាពផ្លូវដែក : បង្កើនសុវត្ថិភាពផ្លូវដែករឹងមាំ សន្សំសំចៃថវិកាថែទាំ និងបន្ថយផលប៉ះពាល់បរិស្ថាននិងជីវៈចម្រុះ
- សុខដុមនីយកម្មផ្លូវដែកនិងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀត : ធានាភាពសុខដុមនីយកម្មជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងទៀតដូចជាប្រព័ន្ធលូ ឧបករណ៍បម្រើសេវាសាធារណៈ ច្រកផ្លូវចេញចូល ឆ្លងកាត់និងជ្រាលម្ខសម្រាប់អភិវឌ្ឍន៍សំណង់សិល្បការ្យផ្លូវដែកនាពេលអនាគត
- ប្រតិបត្តិការផ្លូវដែកនិងចលនារថភ្លើងមានភាពរលូនដោយគ្មានការរំខានឬរាំងស្ទះ : ធានាកាត់បន្ថយការប្រើប្រាស់ដីចំណីផ្លូវដែកមិនស៊ីចង្វាក់គ្នា ដោយជំរុញឱ្យមានការអភិវឌ្ឍប្រកបដោយភាពស៊ីចង្វាក់គ្នា ដែលចៀសវាងការរំខានឬរាំងស្ទះដល់ប្រតិបត្តិការផ្លូវដែក



ស G H8

- ផ្លាស់ប្ដូរទម្រង់ដឹកជញ្ជូនផ្លូវដែកនិងបរិការណ៍សេដ្ឋកិច្ច សង្គមកិច្ច ៖ ជានាការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកឆ្លើយតបនឹងកំណើនសេដ្ឋកិច្ចនិងប្រជាពលរដ្ឋ ជាពិសេសតំបន់ទីក្រុងឬតំបន់ទីប្រជុំជននានាដែលមានដង់ស៊ីតេប្រជាពលរដ្ឋខ្ពស់ ដើម្បីដោះស្រាយការកកស្ទះចរាចរណ៍ កាត់បន្ថយការបំពុលបរិយាកាសទីក្រុង លើកកម្ពស់សុវត្ថិភាពសាធារណៈ និងបរិស្ថានក្នុងប្រតិបត្តិការផ្លូវដែក។

## ផ្នែកទី២
## ការកំណត់ដីចំណីផ្លូវដែកនៅតាមបណ្ដាញផ្លូវដែក

**មាត្រា១៧ .-**

ដីចំណីផ្លូវដែក ត្រូវបានកំណត់ដូចតទៅ៖

- ដីចំណីផ្លូវដែកក្រៅរាជធានី ក្រុង និងទីប្រជុំជន ត្រូវមានប្រវែង៣០(សាមសិប)ម៉ែត្រពីសងខាងអ័ក្សផ្លូវដែក
- ដីចំណីផ្លូវដែកដែលស្ថិតនៅក្នុងតំបន់ព្រៃភ្នំនិងតំបន់ដែលមានថ្មរមៀលធ្លាក់ឬតំបន់ព្រៃខ្ពស់ ត្រូវមានប្រវែង១០០(មួយរយ)ម៉ែត្រពីសងខាងអ័ក្សផ្លូវដែក
- ដីចំណីផ្លូវដែកក្នុងរាជធានី ក្រុង និងទីប្រជុំជន ត្រូវកំណត់និងរក្សាទុកទៅតាមទីតាំងជាក់ស្ដែង និងមានការឯកភាពពីគណៈកម្មាធិការគ្រប់គ្រងនិងប្រើប្រាស់ដីចំណីផ្លូវដែក
- ដីបរិវេណស្ថានីយរថភ្លើងត្រូវអនុវត្តតាមប្លង់ដែលមានជាធរមាន
- ផ្ទៃលម្ហឆ្លងកាត់លើផ្លូវដែកត្រូវមានកម្ពស់យ៉ាងតិច៩(ប្រាំបួន)ម៉ែត្រពីខ្នងដែករ៉ែ។

ការកំណត់អក្ស័ដីចំណីផ្លូវដែកត្រូវធ្វើឡើងតែមួយលើកគត់។

**មាត្រា១៨ .-**

ដីចំណីផ្លូវដែកទាំងសងខាងនិងផ្ទៃក្រោមដីនៃផ្លូវដែកក្នុងរាជធានី ក្រុង និងទីប្រជុំជននានានៃខេត្ត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១៩ .-**

ដីបរិវេណស្ថានីយរថភ្លើងត្រូវចុះបញ្ជីជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ សម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យផ្លូវដែក។ ចំពោះដីបរិវេណស្ថានីយរថភ្លើងដែលមិនទាន់បានកំណត់ជាក់លាក់ សមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែកត្រូវសហការជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដើម្បីធ្វើការដោះស្រាយ និងរៀបចំរក្សាទុកដីបរិវេណស្ថានីយរថភ្លើងទាំងនោះ អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៥
## វិធានការសុវត្ថិភាពផ្លូវដែកនិងការការពារដីចំណីផ្លូវដែក
## ផ្នែកទី១
## វិធានការសុវត្ថិភាពផ្លូវដែក

**មាត្រា២០ .-**

សកម្មភាពដែលត្រូវហាមឃាត់សម្រាប់បម្រើឱ្យវិធានការសុវត្ថិភាពផ្លូវដែក មានដូចខាងក្រោម៖

- ការរំលោភលើដីចំណីផ្លូវដែកនិងដីបរិវេណស្ថានីយរថភ្លើង



05 Ce H8

- ការបើកផ្លូវឆ្លងកាត់ផ្លូវដែក ការសាងសង់ស្ពានអាកាស ផ្លូវរូងក្រោមផ្លូវដែក ឬការងារផ្សេងទៀតដែលឆ្លងកាត់ផ្លូវដែកដោយគ្មានការអនុញ្ញាត
- ការរុះរើឬកែប្រែបរិធាននិងឧបករណ៍បរិក្ខារ ផ្លាកសញ្ញាសុវត្ថិភាពផ្សេងៗដោយគ្មានការអនុញ្ញាត
- ការផ្តល់សញ្ញានិងការរារាំងជាឧបសគ្គដល់ចរាចរណ៍របស់រថភ្លើងដោយគ្មានមូលហេតុច្បាស់លាស់
- ការដើរឆ្លងកាត់របងរបារ ឬរបាំង ឬឆ្លងកាត់ផ្លូវដែកខុសពីកន្លែងដែលបានអនុញ្ញាត
- ការលែងសត្វពាហនៈឬការលក់ដូរនៅលើឬកៀកនឹងផ្លូវដែកឬរបៀងសុវត្ថិភាពចរាចរណ៍ផ្លូវដែក
- ការធ្វើសកម្មភាពផ្សេងទៀតដែលរំខានឬរារាំងចរាចរណ៍តាមផ្លូវដែក។

## ផ្នែកទី២
## វិធានការការពារដីចំណីផ្លូវដែក

### មាត្រា២១ .-

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រងនិងប្រើប្រាស់ដីចំណីផ្លូវដែក ដែលដឹកនាំសម្របសម្រួលដោយក្រសួងសាធារណការនិងដឹកជញ្ជូន និងមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ក្នុងគោលបំណងដើម្បីធានានិងរក្សាទុកដីចំណីផ្លូវដែកសម្រាប់បម្រើដល់ការអភិវឌ្ឍនិងសុវត្ថិភាពវិស័យផ្លូវដែកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រកបដោយនិរន្តរភាពនិងចីរភាព។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការគ្រប់គ្រងនិងប្រើប្រាស់ដីចំណីផ្លូវដែក ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

### មាត្រា២២ .-

គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវចូលរួមសហការនិងអនុវត្តភារកិច្ចតាមការសម្របសម្រួលរបស់គណៈកម្មាធិការគ្រប់គ្រងនិងប្រើប្រាស់ដីចំណីផ្លូវដែក និងមិនត្រូវអនុញ្ញាតឱ្យសាងសង់សំណង់គ្រប់ប្រភេទ រួមទាំងដំណាំអចិន្ត្រៃយ៍ នៅតាមដីចំណីផ្លូវដែកនិងដីតំបន់អភិវឌ្ឍន៍ផ្លូវដែកដូចមានចែងក្នុងមាត្រា១៧ មាត្រា១៩ និងមាត្រា៣១នៃអនុក្រឹត្យនេះ។

### មាត្រា២៣ .-

ក្រសួងសាធារណការនិងដឹកជញ្ជូនត្រូវរៀបចំដំឡើងផ្លាកសញ្ញា ដើម្បីកំណត់ព្រំដីចំណីផ្លូវដែកនៅតាមទីតាំងដែលចាំបាច់និងត្រូវផ្សព្វផ្សាយជាសាធារណៈ។

ក្រសួងសាធារណការនិងដឹកជញ្ជូនត្រូវចេញសេចក្តីប្រកាសឬសេចក្តីណែនាំ ដើម្បីកំណត់ការប្រើប្រាស់ដីចំណីផ្លូវដែកសម្រាប់ជាប្រយោជន៍សាធារណៈនិងឯកជន ដូចជាការដឹកកប់ខ្សែបណ្តាញទូរគមនាគមន៍ ខ្សែបណ្តាញអគ្គិសនី បំពង់បណ្តាញទឹកស្អាត ប្រព័ន្ធលូ ប្រព័ន្ធបណ្តាញបំពង់បង្ហូរនិងចែកចាយផលិតផលប្រេងកាតនិងឧស្ម័នធម្មជាតិ ឬការបោះបង្គោលបណ្តាញទូរគមនាគមន៍ បង្គោលបណ្តាញអគ្គិសនី ផ្ទាំងផ្សព្វផ្សាយពាណិជ្ជកម្ម និងសកម្មភាពប្រហាក់ប្រហែលផ្សេងៗទៀតពាក់ព័ន្ធជាមួយនឹងដីចំណីផ្លូវដែក។

### មាត្រា២៤ .-

រាល់ការប្រើប្រាស់ដីចំណីផ្លូវដែកសម្រាប់ជីកកប់ខ្សែបណ្តាញទូរគមនាគមន៍ ខ្សែបណ្តាញអគ្គិសនី បំពង់បណ្តាញទឹកស្អាត ប្រព័ន្ធលូ ប្រព័ន្ធបណ្តាញបំពង់បង្ហូរនិងចែកចាយផលិតផលប្រេងកាតនិងឧស្ម័នធម្មជាតិ ឬការបោះបង្គោលបណ្តាញទូរគមនាគមន៍ បង្គោលបណ្តាញអគ្គិសនី ផ្ទាំងផ្សព្វផ្សាយពាណិជ្ជកម្ម និងសកម្មភាព



ß G H8

ប្រហាក់ប្រហែលផ្សេងៗទៀតលើដីចំណីផ្លូវដែក ក្នុងគោលបំណងសេវាកម្មស្វែងរកកម្រៃសេវា ត្រូវស្នើសុំការអនុញ្ញាត និងបង់កម្រៃសេវានិងថ្លៃជួសជុលការខូចខាតជូនសមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក។

ការបង់កម្រៃសេវានិងថ្លៃជួសជុលការខូចខាតដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវលើកលែងក្នុងករណីបម្រើដល់ប្រយោជន៍សាធារណៈ សន្តិសុខ និងកិច្ចការពារជាតិ ដែលទទួលបានការឯកភាពពីរាជរដ្ឋាភិបាល។

ការបង់កម្រៃសេវានិងថ្លៃជួសជុលការខូចខាតដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២៥ .-**

មន្ត្រីមានសមត្ថកិច្ចដែលត្រូវចាត់តាំងឱ្យចុះធ្វើការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងអនុវត្តវិធានការច្បាប់ ក្នុងការគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក ត្រូវមានលិខិតបញ្ជាបេសកកម្មឬលិខិតឧទ្ទេសនាមដែលចេញដោយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសាមី។

នីតិវិធីនៃការអនុវត្តការកិច្ចត្រួតពិនិត្យលើការគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា២៦ .-**

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូនមានសិទ្ធិបដិសេធឬបញ្ជាឱ្យរុះរើរាល់គម្រោងសាងសង់ ជួសជុល ថែទាំ និងកែសម្រួលផ្លូវឆ្លងកាត់ផ្លូវដែកដែលខុសលក្ខណៈបច្ចេកទេស ឬតម្រូវឱ្យកែប្រែលក្ខណៈបច្ចេកទេសឡើងវិញ នៅពេលទទួលបានរបាយការណ៍បច្ចេកទេសសុវត្ថិភាពផ្លូវដែក។

**មាត្រា២៧ .-**

បុគ្គលដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីមានសមត្ថកិច្ច អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រសួងសាធារណការនិងដឹកជញ្ជូន ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងអំពីវិធានការ ឬអាចប្ដឹងទៅតុលាការមានសមត្ថកិច្ច តាមនីតិវិធីជាធរមានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីវិធានការ។

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូនត្រូវចេញសេចក្ដីសម្រេចលើបណ្ដឹងតវ៉ា ដោយបញ្ជាក់អំពីមូលហេតុ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបណ្ដឹងតវ៉ា។

ក្នុងករណីដែលបុគ្គលណាម្នាក់មិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន បុគ្គលនោះមានសិទ្ធិប្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ច តាមនីតិវិធីជាធរមានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្ដីសម្រេច។

ក្នុងករណីរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន មិនសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេលដូចកំណត់ក្នុងកថាខណ្ឌទី២ខាងលើ ម្ចាស់បណ្ដឹងអាចប្ដឹងទៅតុលាការក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់នោះ។

## ជំពូកទី៦
## ថវិកាសម្រាប់ការថែទាំផ្លូវឆ្លងកាត់ផ្លូវដែកនិងគ្រប់គ្រងដីចំណីផ្លូវដែក

**មាត្រា២៨ .-**

ថវិកាប្រើប្រាស់លើការថែទាំផ្លូវឆ្លងកាត់ផ្លូវដែកនិងគ្រប់គ្រងដីចំណីផ្លូវដែក ត្រូវរៀបចំជាកញ្ចប់ថវិកាមួយ



ស ប 48

ដោយឡែកនៅក្នុងឧបសម្ព័ន្ធថវិការបស់ក្រសួងសាធារណការនិងដឹកជញ្ជូន និងផ្គត់ផ្គង់ដោយមូលនិធិដែលបាន មកពីប្រភពហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ និងដោយប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់បំពេញការងារ របស់ខ្លួនឱ្យមានប្រសិទ្ធភាព។

## ជំពូកទី៧
## បទប្បញ្ញត្តិដោយឡែក

**មាត្រា២៩ .-**

រដ្ឋធ្វើការទូទាត់សំណងចំពោះកម្មសិទ្ធិករស្របច្បាប់ដែលទទួលរងផលប៉ះពាល់ដោយសារការអភិវឌ្ឍ និង/ឬការផ្លាស់ប្ដូរអ័ក្សផ្លូវដែកនៃការកំណត់ដីចំណីផ្លូវដែកជាថ្មី អនុលោមតាមច្បាប់ស្ដីពីអស្សាមិករណ៍និងលិខិត បទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៨
## ទណ្ឌកម្ម

**មាត្រា៣០ .-**

បុគ្គលដែលសាងសង់ផ្លូវឆ្លងកាត់ផ្លូវដែកដោយគ្មានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែក និងដីចំណីផ្លូវដែក និងបុគ្គលដែលរំលោភសាងសង់សំណង់គ្រប់ប្រភេទឬដាំដំណាំអចិន្ត្រៃយ៍ក្នុងដីចំណីផ្លូវដែក និងដីបរិវេណស្ថានីយរថភ្លើង ត្រូវផ្ដន្ទាទោសតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៩
## អន្តរប្បញ្ញត្តិ

**មាត្រា៣១ .-**

រាល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជាបង្គោលបណ្ដាញទូរគមនាគមន៍ បង្គោលបណ្ដាញអគ្គិសនី បំពង់បណ្ដាញ ទឹកស្អាត ប្រព័ន្ធលូ ប្រព័ន្ធបណ្ដាញបំពង់បង្ហូរនិងចែកចាយផលិតផលប្រេងកាតនិងឧស្ម័នធម្មជាតិ បណ្ដាញ ផ្សេងៗនៅលើដីឬក្រោមដី និងផ្ទាំងផ្សព្វផ្សាយនានា ដែលមានស្រាប់និងមិនរៀបរយនៅក្នុងទីតាំងដីចំណី ផ្លូវដែក សមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែកត្រូវសហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរមាន សមត្ថកិច្ចពាក់ព័ន្ធ និងដៃគូផ្សេងទៀត ដើម្បីពិភាក្សា ដោះស្រាយ និងលើកគម្រោងរុះរើឬសាងសង់ឡើងវិញ ស្របតាមស្ថានភាពភូមិសាស្ត្រនៃទីតាំងនីមួយៗ។

ដោយឡែក ចំពោះហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ដែលមានលក្ខណៈ ពិសេសមិនអាចរុះរើបាន ត្រូវរក្សាទីតាំងនៅក្នុងដីចំណីផ្លូវដែកដដែលនិងត្រូវធានាសុវត្ថិភាពចរាចរណ៍ផ្លូវដែក។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**មាត្រា៣២ .-**

មាត្រា៩និងមាត្រា១០នៃអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្ដីពីការ គ្រប់គ្រងដីចំណីតាមបណ្ដាញផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧រោច ខែ អស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

**ប៉េង ពោធិ៍នា**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០២៥
ស្ដីពីការគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក

## សទ្ទានុក្រម

១- **ការអភិវឌ្ឍផ្លូវដែក** សំដៅដល់ការស្ថាបនាផ្លូវថ្មី ការស្តារឡើងវិញ និង/ឬការកែលម្អផ្លូវដែក។

២- **ដីចំណីផ្លូវដែក** សំដៅដល់ផ្ទៃដីនៅសងខាងអ័ក្សនៃផ្លូវដែក ធ្លាលម្អផ្ទៃខាងលើ និងផ្ទៃខាងក្រោម ដែលជាផ្នែកដ៏សំខាន់មួយសម្រាប់ប្រើប្រាស់លើហេដ្ឋារចនាសម្ព័ន្ធបម្រុងទុកសម្រាប់អភិវឌ្ឍក្នុងវិស័យផ្លូវដែក ប្រតិបត្តិការប្រកបដោយសុវត្ថិភាព និងការការពារបរិស្ថានសង្គម។

៣- **ដីតំបន់អភិវឌ្ឍន៍ផ្លូវដែក** សំដៅដល់ដីដែលឋិតនៅសងខាងផ្លូវដែក ឬដីដែលឋិតនៅក្នុងឬក្រៅបរិវេណស្ថានីយរថភ្លើងបម្រុងទុកសម្រាប់ការអភិវឌ្ឍវិស័យផ្លូវដែក ដែលបម្រើដល់ការដឹកជញ្ជូនតាមផ្លូវដែកនិងសេវាផ្សេងៗក្រៅពីការដឹកជញ្ជូនតាមផ្លូវដែក ដូចជាការសាងសង់សណ្ឋាគារនិងផ្សារទំនើប។

៤- **ឋបនីយកណ្ឋផ្លូវដែក** សំដៅដល់គ្រឿងឧបករណ៍និងសម្ភារៈបរិក្ខារបំពាក់ឱ្យផ្លូវដែក ដូចជាខ្សែផ្លូវដែក មធ្យោបាយដឹកជញ្ជូន ស្ថានីយរថភ្លើង សញ្ញាចរាចរណ៍ ទីកន្លែងភស្តុភារកម្ម រោងជាងជួសជុលនិងថែទាំផ្លូវដែក រោងជាងជួសជុលនិងថែទាំក្បាលម៉ាស៊ីន និងទូរថភ្លើង ឧបករណ៍ថាមពលអគ្គិសនី ព័ត៌មាន និងទំនាក់ទំនង ឧបករណ៍ធ្វើតេស្តសាកល្បងនិងស្រាវជ្រាវបច្ចេកទេសផ្លូវដែក គ្រឿងបរិក្ខារបម្រើឱ្យការបណ្តុះបណ្តាលនិងអប់រំការគ្រប់គ្រងផ្លូវដែកនិងជំនាញឯកទេសផ្លូវដែក គ្រឿងបរិក្ខារនិងឧបករណ៍វិស្វកម្ម និងស្ថាបត្យកម្មដែលបម្រើឱ្យការសាងសង់ជួសជុល ថែទាំ និងប្រតិបត្តិការផ្លូវដែក។

៥- **បរិក្ខារផ្លូវដែក** សំដៅដល់របង របាំងការពារ ផ្ទាំង និងផ្លាកសញ្ញា ភ្លើងបំភ្លឺ ភ្លើងសញ្ញាចរាចរណ៍ កន្លែងសម្រាកទីជំហាប់ ទីចំណត ស្ថានីយរថភ្លើង ព្រមទាំងសម្ភារៈ និងសំណង់ផ្សេងៗទៀត ដែលបានស្ថាបនាក្នុងដីចំណីផ្លូវដែក ដើម្បីជួយសម្រួលដល់ការប្រើប្រាស់ឬបម្រើផលប្រយោជន៍ផ្លូវដែក។

៦- **បរិធាន** សំដៅដល់ឧបករណ៍សម្រាប់ផ្លាស់ប្តូរទិសដៅផ្លូវដែក។

៧- **ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព** សំដៅដល់វិធានការប្រមូលផ្តុំ ក្នុងការចាត់ចែងនិងអនុវត្តដោយសមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក ដើម្បីធានាសុវត្ថិភាពចរាចរណ៍ផ្លូវដែក។

៨- **បុគ្គលដែលប្រើប្រាស់ច្រកផ្លូវឆ្លងកាត់ផ្លូវដែក** សំដៅដល់ជនណាមួយដែលទទួលបានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែកនិងដីចំណីផ្លូវដែក ដើម្បីសាងសង់ផ្លូវឆ្លងកាត់ផ្លូវដែកសម្រាប់ជាច្រកចេញចូលទីតាំងកម្មសិទ្ធិអចលនទ្រព្យរបស់ខ្លួន។

៩- **ផ្លូវឆ្លងកាត់ផ្លូវដែក** សំដៅដល់ចំណុចប្រសព្វគ្នារវាងផ្លូវដែកនិងផ្លូវថ្នល់ និងជាមួយផ្លូវផ្សេងៗទៀត ដែលមានកម្រិតកម្ពស់ដូចគ្នា។

១០- **ផ្លូវដែក** សំដៅដល់ប្រព័ន្ធដឹកជញ្ជូនដែលផ្សំឡើងដោយសមាសធាតុអង្គបង្គុំផ្សេងៗ រួមមានសំណង់ផ្លូវដែក ឋបនីយកណ្ឋផ្លូវដែក យានផ្លូវដែក ប្រតិបត្តិការពាក់ព័ន្ធ និងភាពចាំបាច់ផ្សេងទៀត សម្រាប់ដឹកជញ្ជូនអ្នកដំណើរ ឬទំនិញ។

១១- **មន្ត្រីមានសមត្ថកិច្ច** សំដៅដល់មន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងវិស័យផ្លូវដែក ដែលត្រូវបានចាត់តាំងឱ្យចុះអប់រំណែនាំ ផ្សព្វផ្សាយ និងអនុវត្តវិធានការច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងផ្លូវឆ្លងកាត់និងដីចំណីផ្លូវដែក។

១២- **រថភ្លើង** សំដៅដល់ក្បាលម៉ាស៊ីនភ្ជាប់ដោយទូរថភ្លើងនិងយានដែលមានកង់ធ្វើចលនារត់លើផ្លូវដែក។

១៣- **សំណង់ផ្លូវដែក** សំដៅដល់ផ្លូវដែលសាងសង់សម្រាប់ឱ្យរថភ្លើងធ្វើចរាចរណ៍ដឹកជញ្ជូនអ្នកដំណើរនិងទំនិញគ្រប់ប្រភេទ រួមទាំងសំណង់សិល្បការ្យនិងបរិក្ខារផ្លូវដែក។

១៤- **សំណង់សិល្បការ្យផ្លូវដែក** សំដៅដល់សំណង់ស្ពាន លូ ជញ្ជាំងទប់ដី ប្រព័ន្ធរំដោះទឹក និងសំណង់រូបវន្តផ្សេងៗទៀត ដែលផ្តល់សុវត្ថិភាពនិងស្ថិរភាពដល់ផ្លូវដែក។

១៥- **សម្ភារៈយានផ្លូវដែក** សំដៅដល់ក្បាលម៉ាស៊ីន ទូរថភ្លើង និង/ឬគ្រឿងឧបករណ៍នានាដែលអាចទាញឬរំកិលនៅលើផ្លូវដែក។

១៦- **អ្នកបើកបរ** សំដៅដល់អ្នកបញ្ជាយាន គិតទាំងអ្នកជិះសត្វ អ្នកដឹកសត្វ និងអ្នកបរសត្វនៅលើផ្លូវ។

១៧- **អ្នកពាក់ព័ន្ធផ្លូវដែក** សំដៅដល់អ្នកគ្រប់គ្រង អ្នកសាងសង់ អ្នកផ្តល់ហិរញ្ញប្បទាន ឬសម្បទានិក អ្នកត្រួតពិនិត្យ អ្នកថែទាំ អ្នកដឹកជញ្ជូន និងអ្នកប្រើប្រាស់ អ្នករស់នៅសងខាងផ្លូវ អ្នកផ្គត់ផ្គង់សម្ភារៈគ្រឿងចក្រ បរិក្ខារផ្លូវដែក។